ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ : 009/18 កសស.អល

លទ្ធកម្ម ក.ស.ស

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់រថយន្តជួសជុលចល័តផ្នែកអគ្គីសនី ចំនួន ០១គ្រឿង (ថ្មី) និងរថយន្តជួសជុលចល័តផ្នែកគ្រឿងម៉ាស៊ីន ចំនួន ០១គ្រឿង (ថ្មី) ផលិតផលប្រទេសជប៉ុន សម្រាប់ឆ្នាំ ២០១៨

កំពង់ផែស្វយ័តក្រុងព្រះសីហនុសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា: កំពង់ផែស្វយ័តក្រុងព្រះសីហនុនឹងដាក់អោយដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់រថយន្តជួសជុលចល័តផ្នែកអគ្គីសនី ចំនួន ០១គ្រឿង (ថ្មី) និងរថយន្តជួសជុលចល័តផ្នែកគ្រឿងម៉ាស៊ីន ចំនួន ០១គ្រឿង (ថ្មី) ផលិតផលប្រទេសជប៉ុន សម្រាប់ឆ្នាំ ២០១៨ ជូនកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

កំពង់ផែស្វយ័តក្រុងព្រះសីហនុបានរៀបចំឯកសារសំរាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃនិងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃនាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ ដែលមានអាសយដ្ឋាន : កំពង់ផែស្វយ័តក្រុងព្រះសីហនុ ចាប់ពីថ្ងៃ **១២** ខែ **វិច្ឆិកា ឆ្នាំ ២០១៨** តទៅ រៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទំនាក់ទំនងលេខ 012 912 034 ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង **៩:០០ព្រឹក** ថ្ងៃទី **១២** ខែ **ធ្នូ ឆ្នាំ ២០១៨** ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ តាមអាសយដ្ឋានខាងលើ វេលាម៉ោង **៩:០០ ព្រឹក** ថ្ងៃទី **១២** ខែ **ធ្នូ ឆ្នាំ ២០១៨** ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

*ថ្ងៃ ព្រហស្បតិ៍ ១កើត ខែ កត្តិក ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២*

*ខេត្តព្រះសីហនុ,ថ្ងៃទី ០៨ ខែ ១១ ឆ្នាំ ២០១៨*

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជាប្រធានអគ្គនាយក**
**និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

**លូ_គឹមឈន់**

ចម្លងជូន
- "អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ"
- "អង្គភាពប្រឆាំងអំពើពុករលួយ"